**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ២៨១ប្រ
ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៤

**សាលដីកា**
លេខៈ២៨០
ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ................ ជាចៅក្រមរបាយការណ៍
៣-លោក ............... ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក .............. ជាចៅក្រម

**ក្រឡាបញ្ជី**

-កញ្ញា ................

**តំណាងមហាអយ្យការ**

-លោក .............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការរដ្ឋប្បវេណីលេខ១៤(ឈ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧០ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់សាលឧទ្ធរណ៍រវាង ៖

ដើមចោទឈ្មោះលម(ជាចុងបណ្តឹងសាទុក្ខ) អាយុ៤០ឆ្នាំ មុខរបរនៅផ្ទះ ទីលំនៅផ្ទះលេខ៩ ផ្លូវលេខ១៨៣ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន ក្រុងភ្នំពេញ ។

មានមេធាវីលោក ............។

ចុងចម្លើយឈ្មោះយរ ហៅអ៊ឹង យរ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៥០ឆ្នាំ មុខរបរពាណិជ្ជករ ទីលំនៅផ្ទះលេខ១៣៤D ផ្លូវសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

មានមេធាវីលោក........... និងលោក........... ។

<u>**កម្មវត្ថុបណ្តឹងៈ**</u>ប្តឹងសុំកត់ឃាត់ទ្រព្យសម្បត្តិរួម ទុកជាបណ្តោះអាសន្ន •

បានឃើញបណ្តឹងសាទុក្ខលេខ៩៧ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះយរ ហៅអ៊ឹង យរ ប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ១៤(ឈ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៨១ប្រ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងសុំដីកាសម្រេច ចុះថ្ងៃទី១៥-១០-២០០៣ របស់អ្នកស្រីមួង ធនលាភី ជាមេធាវីតំណាងឱ្យឈ្មោះលមប្តឹងសុំដីកាសម្រេច ដើម្បីឱ្យឈ្មោះលមសហការជាមួយកងរាជអាវុធហត្ថ និងឃោជាខេត្តកោះកុង គ្រប់គ្រងរក្សាទុកជាបណ្តោះអាសន្ននូវគ្រឿងចក្រពីលេខ១ ដល់ លេខ២៦ ស្ថិតនៅខេត្តកោះកុង និងផ្ទះវីឡានៅភូមិ៤ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ផ្ទះមួយល្វែង នៅស្រុកស្រែអំបិល ខេត្តកោះកុង ផ្ទះវីឡាលេខ៩ផ្លូវលេខ១៨៣ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន ក្រុងភ្នំពេញ និងសណ្ឋាគារមនោរម្យនៅខេត្តស្វាយរៀង ដែលតុលាការក្រុងភ្នំពេញ បានកត់ឃាត់ តាមដីកាសម្រេចតាមពាក្យសុំលេខ ១៤(គ) ចុះថ្ងៃទី១៤-៨-២០០៣ និងមិនឱ្យប្រើប្រាស់គ្រឿងចក្រពីលេខ១ ដល់លេខ២៦ នេះមិនឱ្យលក់-ដូរ-ជួល ឬបញ្ចាំ ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ១៤(គ) ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី០៤-៨-២០០៣ របស់អ្នកស្រីលមទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-មិនឱ្យលក់ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិឬធ្វើអំណោយទៅអ្នកដទៃទ្រព្យសម្បត្តិដូចខាងក្រោម :

-ផ្ទះវីឡាជាប់មាត់សមុទ្រ ឋិតនៅភូមិ៤ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង

-ដី(ទល់មុខផ្ទះ) ភូមិ៤ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង

-ផ្ទះមួយល្វែងឋិតនៅស្រុកស្រែអំបិល ខេត្តកោះកុង

-ដីទំហំប្រហែល៤ហិកតា ឋិតនៅខេត្តកោះកុងដីឋិតនៅជិតស្តូប ខេត្តកោះកុង)

-ដីស្រែបង្ការនៅភូមិបឹងកាឆាង ឃុំប៉ាកខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង លេខB០២៧៩

-ដីចំការខ្ទះរោងចក្រថ្លៃឈើ ទំហំប្រហែល ២៥ហិកតា ឋិតនៅខេត្តកោះកុង

-ផ្ទះវីឡាលទ៩ ផ្លូវលេខ១៨៣ ស្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ

-សណ្ឋាគារមនោរម្យ ឋិតនៅឃុំស្វាយរៀង ស្វែង៣ជាន់$E_0E_1E_2$ ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។

-ព្រៃសម្បទានទំហំ២០ម៉ឺនហិកតា ឋិតនៅខេត្តពោធិសាត់ និងខេត្តបាត់ដំបង

-ដីទំហំ២ហិកតា ៥០អា ឋិតនៅភូមិខ្នៀន សង្កាត់លេខ៣ ទីរួមខេត្តសៀមរាប

-ប្រាក់ចំនួន១៥៦៩៣.៧០០.០០០រៀល(ដប់ប្រាំពាន់ប្រាំមួយរយកៅសិបបីលាន ប្រាំពីររយពាន់រៀលគត់) ជាប្រាក់ថ្លៃការងារស្ថាបនាផ្លូវ ស្ពាន លូ ប្រហែល ១៣៥គ.ម តាមកិច្ចសន្យាលេខ២៧៦សកហវ ប្រាក់នេះត្រូវបើករតនាគារជាតិ ។

-ដីក្បែរវត្តជោតញាណ ឋិតនៅខេត្តកោះកុង

-ដីនៅខេត្តសៀមរាប
-ដី៧០០ហិកតា ឋិនៅតំបន់២៩៧ ខេត្តកោះកុង
-គ្រឿងចក្រមានរាយដូចខាងក្រោមៈ

| | |
|---|---|
| ១-CAT ម៉ែឃោ | ៨គ្រឿង |
| ២- CAT ឈូស | ៥គ្រឿង |
| ៣-CAT លើកឈើ | ៤គ្រឿង |
| ៤- CATTERPIUAR កៀ | ៣គ្រឿង |
| ៥-រ៉ូឡូកិត | ៣គ្រឿង |
| ៦-រ៉ូឡូញាក់ | ៣គ្រឿង |
| ៧-ឡានបែន Thai | ១១គ្រឿង |
| ៨-ឡានបែន | ៣គ្រឿង |
| ៩-ស្ទូច | ២គ្រឿង |
| ១០-ឡានអូស | ៣គ្រឿង |
| ១១-ឡានទឹក | ២គ្រឿង |
| ១២-ម៉ាសទ្រុង | ៣គ្រឿង |
| ១៣-កាំម៉ាស់ | ៣គ្រឿង |
| ១៤-ម៉ាសដឹកឈើ | ៨គ្រឿង |
| ១៥-ប្រដាប់ដាក់ឈើរ៉ឺម៉ក | ៨គ្រឿង |
| ១៦-ម៉ាស៊ីនភ្លើងធំ១,៧៥០kwa | ១គ្រឿង |
| ១៧-ម៉ាស៊ីនតូចក្រហម | ១គ្រឿង |
| ១៨-សំបករូប័រតូច | ២គ្រឿង |
| ១៩-ម៉ាស៊ីនអារឈើប្រហែល | ១០គ្រឿង |
| ២០-ក្បាលអូសដែក | ១គ្រឿង |
| ២១-សាឡង់ | ១គ្រឿង |
| ២២-សំបកអូប័ផ្ទុកមនុស្ស១០០នាក់ | ១គ្រឿង |
| ២៣-ដែកធ្វើស្ពាននៅក្នុងរោងចក្រ | |
| ២៤-គោនៅខេត្តតាកែវប្រមាណ | ១៥០ក្បាល |
| ២៥-ត្រាក់ទ័រឈូសដី | ១គ្រឿង |

២៦-ឡានខូចមួយចំនួន គ្រឿងមួយចំនួន គ្រឿងបន្លាស់

| | |
|---|---|
| ២៧-D6 | ៥គ្រឿង |
| ២៨- D7 | ៦គ្រឿង |
| ២៩-ម៉ៃយោ | ២គ្រឿង |
| ៣០-ឡានបែនប្រហែល | ១២គ្រឿង |
| ៣១-ឡេវ៉ាទ័រចូកឈើ | ៦គ្រឿង |
| ៣២-ត្រាក់ទ័រអូសឈើ LKT | ១០គ្រឿង |
| ៣៣-រ៉ូឡូកិនថ្នល់ | ៣គ្រឿង |
| ៣៤- D8 | ១គ្រឿង |
| ៣៥-ត្រក់ទ័រឈូសដី | ១គ្រឿង |
| ៣៦-ឡានដឹកឈើ | ២០គ្រឿង |
| ៣៧-ម៉ាស៊ីនក្រឡឹង | ១គ្រឿង |
| ៣៨-ម៉ាស៊ីនអារឈើ | ៦គ្រឿង |
| ៣៩-ម៉ាស៊ីន750KWA | ១គ្រឿង |
| ៤០-ឡានតូចមួយបាំងកន្លះ | ២គ្រឿង |
| ៤១-ឡានដឹកប្រេង | ២គ្រឿង |
| ៤២-T5 | ៦គ្រឿង |
| ៤៣-ម៉ាស៊ីនប្រេះប្រវាក់ | ១គ្រឿង ទុកជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។ |

៣-ឲ្យកត់ត្រាទ្រព្យសម្បត្តិទាំងអស់ខាងលើនេះ ទុកជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៤-ឲ្យអ្នកស្រីលមបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់២០០៛ បូករួម២០០៛ ប្រាក់នេះកាត់យកពីប្រាក់២០០៛ ដែលអ្នកស្រីលមបានបង់ទុកជាស្រេចតាមច្បាប់ស្តីពីប្រាកប់ប្រដាប់ក្តី ។

៥-ដីកានេះ មានអានុភាពអនុវត្តភ្លាមៗ ទោះបីជាមានបណ្តឹងទាស់ក៏ដោយ ។

៦-បើភាគីណាមិនសុខចិត្តនិងដីកានេះ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីដីកានេះ ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ១៦(គ) ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅះ

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៥-១០-២០០៣ របស់អ្នកស្រីមួង ធនលាភី មេធាវីតំណាងអ្នកស្រីលមដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ឱ្យអ្នកស្រីលមគ្រប់គ្រងថែរក្សាជាបណ្តោះអាសន្ន:

- ផ្ទះវិឡាលេខ៩ ផ្លូវ១៨៣ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន ក្រុងភ្នំពេញ

-សណ្ឋាគារមនោរម្យឋិតនៅឃុំស្វាយរៀង ខេត្តស្វាយរៀង ។

និងសហការគ្រប់គ្រងថែរក្សាគ្រឿងចក្រពីលេខរៀងទី១ ដល់លេខរៀងទី២៦ ជាមួយកងរាជអាវុធហត្ថកំលាំងឃោធាខេត្តកោះកុង ដែលតុលាការក្រុងភ្នំពេញ បានឃាត់តាមដីកាសម្រេចតាមពាក្យសុំលេខ១៤(គ)ចុះថ្ងៃទី១៤-៨-២០០៣ និងមិនឱ្យប្រើប្រាស់គ្រឿងចក្រពីលេខទី១ ដល់លេខរៀងទី២៦ នេះ ។

៣-ឱ្យអ្នកស្រីមួង ធនលាភី មេធាវីតំណាងអ្នកស្រីលមបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ បូករួម ២០០០៛ ដែលអ្នកស្រីមួង ធនលាភី បានបង់ទុកជាស្រេចតាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៤-ដីកានេះ មានអានុភាពភ្លាមៗ ទោះបីជាមានបណ្តឹងទាស់ក៏ដោយ ។

៥-បើភាគីណាមិនសុខចិត្តនឹងដីកានេះ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល១៥ថ្ងៃគតិចាប់ពីថ្ងៃបានទទួលដំណឹងពីដីកានេះ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៣ របស់ឧកញ៉ាយូ រី ហៅ អ៊ឹង យរ ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចតាមពាក្យសុំលេខ១៦(គ) ចុះថ្ងៃទី១៥-១០-២០០៣ របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចទី២ នៃសេចក្តីសម្រេច ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ០៦ប្រ(គ) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៩-១២-២០០៣ របស់លោកយូ រី ហៅ អ៊ឹងយរ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់ដីកាសម្រេចតាមពាក្យសុំលេខ១៦(គ) ចុះថ្ងៃទី១៥-១០-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ២០០០៛ បូករួម៤.០០០៛ តាមច្បាប់ស្តីពី ប្រាក់ប្រដាប់ក្តី ។

៤-ដីកានេះ មានអានុភាពអនុវត្តភ្លាមៗ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៥-បើភាគីណាមិនសុខចិនឹងងដីកានេះ មានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល០២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៥៨(គ) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះយូ រី ប្តឹងមិនសុខចិត្តនិងដីកាសម្រេចកិច្ចការប្រញាប់លេខ០៦ប្រ(គ) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចវិនិច្ឆ័យសេចក្តីទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៤(ឈ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-១២-២០០៣ របស់ដើមចោទឈ្មោះយូ រី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់ដីកាសម្រេចកិច្ចការប្រញាប់លេខ០៦ប្រ(គ) ចុះថ្ងៃទី១៦-១២-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលចុងបណ្តឹងឧទ្ធរណ៍ឈ្មោះលមបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងលើអាជ្ញាធរតុលាការ៥.០០០៛ សរុប១៣.០០០៛ ។ កាលបើសាលដីកានេះ ចូលជាស្ថាពរហើយ បង្គាប់ឱ្យដើមបណ្តឹងឧទ្ធរណ៍ ឈ្មោះយរ ហៅអ៊ឹងយរ សងប្រាក់១៣.០០០៛ នេះទៅឱ្យចុងបណ្តឹងឧទ្ធរណ៍ឈ្មោះលមវិញ ។

៤-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧-០២-២០០៤ ចំពោះមុខ មេធាវីតំណាងឱ្យដើមចោទ និងមេធាវីតំណាងឱ្យចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥-០៣-២០០៤ កំបាំងមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៩៧ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះយូ រី ហៅអ៊ឹង យរ ប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ១៤(ឈ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះយូ រី និង
មេធាវីស្នួស សាមឿន និងមេធាវី រស់ មុនិន្ទៈ ។

បានឃើញសារណាតប ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះលម។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា សាលដីការដ្ឋប្បវេណីលេខ១៤(ឈ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទម្រង់ និងគតិច្បាប់ហើយ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់លោក យូ រី ។

បានស្តាប់ចម្លើយរបស់ឈ្មោះលមនាពេលសវនាការថា៖ អ្នកស្រីលមបានឆ្លើយថា តាមយោបល់ខ្លួន គឺខ្លួនសុំហាមឃាត់ដដែល ព្រោះថារឿងចក្រនេះ ជារបស់ចាស់ៗ គាត់មិនបានប្រើប្រាស់ទេ ហើយម្យ៉ាងទៀត គាត់បានប្រើប្រាស់ជាង៥០គ្រឿងទៅហើយ ហើយក្នុងរបស់ដែលត្រូវហាមឃាត់នោះ គាត់បានដកយកទៅជួលឱ្យគេ បានប្រាក់យកតែគាត់ទៀត ។ ខ្លួនមិន យល់ព្រមឱ្យគាត់យកទៅប្រើប្រាស់ទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសួស សាមឿន ជាមេធាវីការពារឱ្យលោកយូ រី បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឯកឧត្តមជាទីគោរព អំពីអង្គហេតុ គឺដូចកូនក្តីខ្លួនលើកឡើងក្នុង សារណាការពារអញ្ជឹងថា កូនក្តីខ្លួនបានរៀបការគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ១៩៨១ ហើយរកស៊ីមាន បានជាបង្គួរ អាចបញ្ជូនកូនទៅរៀននៅប្រទេសក្រៅបាន ។ ក្នុងការមានទំនាស់បែកបាក់គ្នានេះភាគីខាងអ្នកស្រីបានប្តឹងលែងលះ ហើយប្តឹងសុំឱ្យតុលាការកត់ត្រាទ្រព្យសម្បត្តិ កូនក្តីខ្លួន មិនជំទាស់ទេ តែនៅចុងក្រោយគាត់ប្តឹងហាមឃាត់ទ្រព្យសម្បត្តិមិនឱ្យប្រើប្រាស់នេះ ទើបកូនក្តីខ្លួនប្តឹងជំទាស់ ជាគោលការណ៍នៅក្នុងការសម្រេចចេញដីកាកិច្ចការប្រញាប់ គឺតុលាការមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ភាគីនោះទេ តែតុលាការបែរជាសម្រេចប៉ះពាល់ដល់អាជីវកម្មរបស់កូនក្តីខ្លួន ដែលមិនអាចយកសំភារៈនោះទៅប្រើប្រាស់បាន ត្រង់ចំណុចនេះហើយដែលកូនក្តីខ្លួនមិនសុខចិត្ត ព្រោះក្រុមហ៊ុនមិនទាន់រំលាយ ឬធ្វើការជំរះបញ្ជីនោះទេ កូនក្តីខ្លួនគ្រាន់តែសុំប្រើប្រាស់ដើម្បីជាប្រយោជន៍ឱ្យក្រុមហ៊ុន មានប្រាក់ខែ បើកឱ្យកម្មករ ព្រោះក្រុមហ៊ុនត្រូវការដំណើរការកស៊ី ។ ខ្លួនសុំសំណូមពរ តុលាការមេត្តាបដិសេធសាលដីកាលេខ១៤(ឈ) របស់សាលាឧទ្ធរណ៍ចោលជាអាសារបង់ និងសុំឱ្យកូនក្តីខ្លួនបានប្រើប្រាស់នូវគ្រឿងចក្រដែលត្រូវបានហាមឃាត់នោះដោយអនុគ្រោះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោករស់ មុនិន្ទៈ ជាមេធាវីការពារឱ្យលោកយូ រី បានធ្វើសេចក្តីសន្និដ្ឋានបន្ថែមពីលើលោកមេធាវីសួស សាមឿន ថាលោក យរ ជាប្រធានក្រុមសាកូ ធ្វើអាជីវកម្មលើព្រៃឈើ និងផ្លូវថ្នល់ ឥឡូវនេះរដ្ឋបានបិទលើអាជីវកម្មឈើហើយ នៅសល់តែអាជីវកម្មធ្វើថ្នល់នេះមួយទេ ដូច្នេះក្នុងសកម្មភាពបច្ចុប្បន្ន គាត់ត្រូវការគ្រឿងចក្រទាំងនោះមកប្រើប្រាស់ ព្រោះក្រុមហ៊ុនគាត់ជាក្រុមហ៊ុនធំ នៅខេត្តកោះកុង ហើយគាត់ជាអ្នកទទួលខុសត្រូវ នៅក្នុងក្រុមហ៊ុន មិនមែនប្រពន្ធគាត់ជាអ្នកទទួលខុសត្រូវទេ តាំងពីបើកប្រាក់ខែឱ្យកម្មករ បង់ពន្ធឱ្យរដ្ឋជាដើម ដូច្នេះក្នុងការហាមឃាត់នេះ ធ្វើឱ្យប៉ះពាល់ដល់ក្រុមហ៊ុន ម្យ៉ាងទៀតរឿងអង្គសេចក្តី សាលាឧទ្ធរណ៍បានកាត់ទ្រព្យសម្បត្តិហាមឃាត់នោះឱ្យមកកូនក្តីខ្លួន ភាគីគាត់មិនបានប្តឹងទាស់ទេ ខ្លួនសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនបានប្រើប្រាស់គ្រឿងចក្រទាំងនោះ ព្រោះក្នុងការប្រើប្រាស់នេះ មិនបានធ្វើឱ្យបាត់បង់អ្វីទេ ព្រោះទ្រព្យសម្បត្តិទាំងនោះ បានចុះបញ្ជីត្រឹមត្រូវហើយ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ...........ជាមេធាវីការពារឱ្យអ្នកស្រីលមបានធ្វើសេចក្តីសន្និដ្ឋានថា ដើម្បីពិនិត្យ និងពិចារណាតាមអង្គហេតុ និងអង្គច្បាប់ ឃើថា ការលើកឡើងរបស់លោកមេធាវី គ្រាន់តែជាការធ្វើឱ្យពិរោះស្តាប់ក្នុងសាច់រឿងតែប៉ុណ្ណោះ ។ ខ្លួនសុំជម្រាបតុលាការថា ទ្រព្យសម្បត្តិគឺគ្រឿងចក្រទាំងនោះ គាត់មិនបានយកទៅប្រើប្រាស់ តាំងពីឆ្នាំ២០០០ ម្ល៉េះ ហើយទ្រព្យទាំងនេះគាត់ថាជារបស់ក្រុមហ៊ុន ដូច្នេះថាជាទ្រព្យរួម ដែលកូនក្តីខ្លួនមានសិទ្ធិគ្រប់គ្រងដែរ គឺមិនមែនជាទ្រព្យឯកជនទេ ក្នុងនោះគាត់បានយកទ្រព្យសម្បត្តិមួយចំនួនទៅជួលឱ្យគេយកលុយតែម្នាក់ឯង មិនបានឱ្យមកកូនក្តីខ្លួនទេ សូម្បីតែអាហារកិច្ចក៏មិនផ្តល់ឱ្យកូនដែរ។ខ្លួនសូមបញ្ជាក់ថា ការសម្រេចហាមឃាត់នោះ មិនប៉ះពាល់ដល់អង្គសេចក្តីទេ ព្រោះតាំងពីឆ្នាំ២០០០ រហូតដល់ឆ្នាំ២០០៤នេះ គាត់បានប្រើប្រាស់នូវគ្រឿងចក្រមួយចំនួនហើយ ព្រោះគ្រឿងចក្រទាំងអស់ មានចំនួន១០២គ្រឿង ហើយគាត់បានប្រើ៥២គ្រឿង នៅសល់៥០គ្រឿង ត្រូវហាមឃាត់នោះ ក្នុងនោះគាត់ក៏បានដកយកទៅជួលឱ្យគេទៀត ។ ការលើកឡើងរបស់លោកមេធាវី គឺលើកយកអង្គសេចក្តីមកចូលក្នុងកិច្ចការប្រញាប់ ដូច្នេះខ្លួនសុំឲ្យតុលាការមេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូលត្បិតអ៊ីរឿងអង្គសេចក្តីក៏បានមកដល់តុលាការកំពូល ដើម្បីឱ្យតុលាការពិចារណាបានដែរ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណាលោកយរ ចម្លើយអ្នកស្រីលមនិងសេចក្តីសន្និដ្ឋានកាពាររបស់មេធាវីគូភាគី .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៩៧ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៤ របស់លោកយូ រី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថាលោក យូ រី បានប្តឹងឧទ្ធរណ៍ពីដីកាសម្រេចកិច្ចការប្រញាប់លេខ០៦ប្រ(គ) ចុះថ្ងៃទី១៦-១២-២០០៣ របស់តុលាការក្រុងភ្នំពេញទាំងមូលមែន ប៉ុន្តែនៅពេលសវនាការ នៅសាលាឧទ្ធរណ៍ លោកមេធាវីចុងចម្លើយបានតវ៉ាតែលើការហាមប្រាមមិនឱ្យប្រើប្រាស់គ្រឿងចក្រពីលេខ១ ដល់លេខ២៦ ប៉ុណ្ណោះ នៅក្នុងសារណា ចុះថ្ងៃទី២៧-៧-២០០៤ របស់លោកយូ រី ដែលបានដាក់ជូនតុលាការកំពូល ក៏លោកបានលើកឡើង មិនសុខចិត្តតែលើការហាមឃាត់មិនឱ្យប្រើប្រាស់គ្រឿងចក្រដែរ ។ ប៉ុន្តែនៅក្នុងចំនួនគ្រឿងចក្រដែលបានហាមឃាត់ក្នុងដីកាសម្រេចតាមពាក្យសុំលេខ១៤(គ)ចុះថ្ងៃទី១៤-៨-២០០៣

របស់តុលាការក្រុងភ្នំពេញពីលេខរៀងទី១ ដល់លេខរៀងទី២៦ ឃើញថា លេខរៀងទី២៤ និង២៦ ពុំមែនជាឧបករណ៍ចាំបាច់ប្រើប្រាស់សម្រាប់ធ្វើថ្នល់ទេ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចហាមឃាត់មិនឱ្យចុងចម្លើយប្រើប្រាស់គ្រឿងចក្រខាងលើនេះ ដោយអាងហេតុថា គ្រឿងចក្រនេះ ឈប់ប្រើប្រាស់តាំងពីឆ្នាំ២០០០ មកនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះគ្រឿងចក្រទាំងនោះ បានហាមឃាត់ការលក់ដូរជួលបញ្ចាំផ្ទេរសិទ្ធិឬធ្វើ អំណោយតាមដីកាសម្រេចតាមពាក្យសុំលេខ១៤(គ) ចុះថ្ងៃទី១៤-៨-២០០៣ របស់តុលាការក្រុង ភ្នំពេញរួចហើយ ហើយការហាមឃាត់ការប្រើប្រាស់គ្រឿងចក្រនេះ បានធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់គួភាគី ។ម្យ៉ាងទៀតអាជីវកម្មធ្វើស្ពានថ្នល់នេះ មានពេលខ្លះប្រើ ហើយក៏មាន ពេលខ្លះទំនេរដែរ ។

-យល់ឃើញថា លោកយូ រី បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ហើយមេធាវីលោកក៏បានមកចូលរួមដែរប៉ុន្តែលោកពុំបានមកចូលរួមទេដូច្នេះតុលាការកំពូលជំនុំកំបាំងមុខចាត់ទុកជាចំពោះ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៤(ឈ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ហើយលើកលែងតែការហាមឃាត់មិនឱ្យប្រើប្រាស់គ្រឿងចក្រ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ ចំបាំងមុនចុងចម្លើយ**

១-ទទួលបណ្តឹងសាទុក្ខលេខ៩៧ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៤ របស់លោកយូ រី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងគតិច្បាប់ខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១៤ឈ ចុះថ្ងៃទី០៥ខែមីនាឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ទុកជាបានការលើកលែងតែការហាមប្រើប្រាស់គ្រឿងចក្រដែលត្រូវទុកជាមោឃៈដោយឥតបង្វិល ។

៣-អនុញ្ញាតឱ្យលោកយូ រី មានសិទ្ធិប្រើប្រាស់ជាបណ្តោះអាសន្ននូវគ្រឿងចក្រ ដែលបានហាមឃាត់ និងកត់ត្រាពីលេខរៀងទី១ ដល់ ២៥ លើកលែងលេខរៀងទី២៤ ដែលបានកត់ត្រា និងហាមឃាត់ការលក់ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិឬធ្វើអំណោយទៅអ្នកដទៃ នៅក្នុងដីកាសម្រេច តាមពាក្យសុំលេខ១៤(គ) ចុះថ្ងៃទី១៤-៨-២០០៣ ជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៥០០០៛ ដែលលោកយូ រី បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប ១៩.០០០៛

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤ ។